# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transparency

ផ្ទះលេខ ៥១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរសព្ទ័លេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cambodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៤

# ពត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រពត៌មានប្រចាំខែ
## Monthly Newsletter

### មាតិកាពត៌មាន

- សិក្ខាកាមដែលបានបញ្ចប់វគ្គការងារអភិវឌ្ឍន៍សហគមន៍ បានបង្កើតជាបណ្តាញ.... ២
- ជំណឹងជ្រើសរើសបុគ្គលិក.............................................. ៣
- គេរកឃើញប្រភេទផ្តាសាយបក្សីនៅថៃ ធន់នឹងថ្នាំពេទ្យ..................... ៥
- សហរដ្ឋអាមេរិក និងប្រទេសកម្ពុជាធ្វើការរួមគ្នា ប្រយុទ្ធប្រឆាំងជំងឺផ្តាសាយបក្សី... ៦
- បន្លែបង្ការ ជីសើម និងសំរាម: ការធានាសុវត្ថិភាពស្បៀងនៅភ្នំពេញ.......... ៧
- ក្រុមមន្ត្រី និងកងរាជអាវុធហត្ថ បានដុតបំផ្លាញផ្ទះ១៣០ខ្នង នៅក្នុងព្រៃ......... ៨
- បេក្ខភាពប្រាសាទអង្គរវត្ត ត្រឹមថ្ងៃទី១៥ មីនា ២០០៧ ស្ថិតនៅជួរទី២...... ៩
- សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក.............. ១០

# កម្មវិធីរបស់ ARD

## សិក្ខាកាមដែលបានបញ្ចប់វគ្គការងារអភិវឌ្ឍន៍សហគមន៍ បានបង្កើតជាបណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ (YAD)

នៅបន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍សហគមន៍ នៅអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ សិក្ខាកាមសរុបចំនួន ៣៧នាក់ ដែលមកពីមហាវិទ្យាល័យផ្សេងៗគ្នាក្នុងព្រះរាជាណាចក្រកម្ពុជា បានស្ម័គ្រចិត្តរួមគ្នាជាធ្លុងមួយបង្កើតជាបណ្តាញស្ម័គ្រចិត្ត ដែលមានឈ្មោះថា សកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ Youth Action for Development (YAD) ក្នុងគោលដៅដើម្បីចូលរួមនៅក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។ YAD នឹងប្រកាន់ខ្ជាប់នូវពាក្យស្លោករបស់ខ្លួនគឺ សមត្ថភាព ចែករំលែក និងអភិវឌ្ឍន៍ ដែលជាការឆ្លុះបញ្ចាំងអោយឃើញពីការតាំងចិត្តក្នុងការកសាងសមត្ថភាពរបស់ខ្លួន ហើយចែករំលែកចំណេះដឹង និងបទពិសោធន៍ជាមួយអ្នកដទៃ ដើម្បីរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិប្រកបដោយឆន្ទៈ និងមនសិការទទួលខុសត្រូវខ្ពស់។

ឆ្លងកាត់ការប្រជុំពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាអស់ជាច្រើនដង និងដោយមានការជួយសំរបសំរួលពីអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៧ កន្លងទៅថ្មីៗនេះ បណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ បានបើកកិច្ចប្រជុំជាផ្លូវការដំបូងរបស់ខ្លួន នៅការិយាល័យអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយបានធ្វើការពិភាក្សា និងអនុម័តនូវលក្ខន្តិកៈ រចនាសម្ព័ន្ធគ្រប់គ្រងរបស់បណ្តាញ ប្រកបដោយលទ្ធផលជាផ្លែផ្កា និងជោគជ័យ។

ដោយមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន បណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ មានទស្សនៈវិស័យមួយច្បាស់លាស់ គឺ *យុវជនកម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ដើម្បីសំរេចបាននូវទស្សនៈវិស័យនេះ បណ្តាញសកម្មភាពយុវជនដើម្បីអភិវឌ្ឍន៍ នឹងបំពេញបេសកកម្មរបស់ខ្លួនតាមរយៈការផ្សព្វផ្សាយ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍នានានៅតាមសហគមន៍។*

បណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ នឹងត្រូវដំណើរការអនុវត្ត គ្រប់គ្រងដោយគណៈគ្រប់គ្រងមួយដែលមានសមាសភាពចំនួន៩ រូប គឺ មានប្រធាន អនុប្រធានបណ្តាញ និងប្រធានក្រុមចំនួន ៧រូប។ បណ្តាញក៏មានយន្តការក្នុងការផ្តល់ប្រឹក្សាដល់គណៈគ្រប់គ្រងផងដែរ គឺផ្តល់ដោយក្រុមប្រឹក្សាពិគ្រោះយោបល់ដែលមានសមាជិកចំនួន៣រូប មកពីអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ២រូប និងពីសេវាយុវជនកម្ពុជា ១រូប។

នៅក្នុងកិច្ចប្រជុំជាផ្លូវការដំបូងរបស់ខ្លួន សមាជិកទាំងអស់របស់បណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ ក៏បានពិភាក្សាផងដែរ អំពីផែនការសំរាប់អនុវត្តនៅបន្ទាប់ពីថ្ងៃបង្កើតបណ្តាញនេះតទៅ ដោយក្នុងនោះ មានផ្តោតសំខាន់ទៅលើការពង្រឹងសមត្ថភាពដល់សមាជិកបណ្តាញសកម្មភាពអប់រំផ្សព្វផ្សាយដល់កុមារ និងជនងាយរងគ្រោះ នៅតំបន់គំនរសំរាមស្ទឹងមានជ័យ ព្រមទាំងផែនការសំរាប់រយៈពេលមួយឆ្នាំក្នុងឆ្នាំ២០០៧នេះ។

*នៅចុងបញ្ចប់នៃកិច្ចប្រជុំ បណ្តាញបានសំរេចកំណត់យកថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៧ វេលាម៉ោង១៤:០០ រសៀល ដើម្បីបើកសិក្ខាសាលាមួយស្តីពីការរៀបចំផែនការឆ្នាំ២០០៧ សំរាប់បណ្តាញសកម្មភាពយុវជន ដើម្បីអភិវឌ្ឍន៍ ដែលនៅក្នុងសិក្ខាសាលានេះ នឹងចូលរួមសំរបសំរួលដោយអ្នកមានបទពិសោធន៍មកពីអង្គការនានា ក្នុងគោលដៅចែករំលែកបទពិសោធន៍ និងជួយក្នុងការកសាងផែនការសំរាប់បណ្តាញអោយទទួលបានជោគជ័យ។ ហេតុនេះ សូមសមាជិកទាំងអស់របស់បណ្តាញ អញ្ជើញចូលរួមនៅក្នុងសិក្ខាសាលានេះកុំបីខាន ដែលនឹងប្រព្រឹត្តិទៅនៅការិយាល័យអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ផ្ទះលេខ ៥១ F ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក។ ពត៌មានផ្សេងៗសូមទំនាក់ទំនងជាមួយលោក សាំង វណ្ណា ប្រធានបណ្តាញ រឺលោក សូ ស៊ីណាត អនុប្រធានបណ្តាញ ដែលមានលេខទូរស័ព្ទ ០១២ ៥៩ ៦១ ៥៥ និង ០១២ ២៤៦ ១៩៨។*

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

# ដំណឹងជ្រើសរើសបុគ្គលិក

| | | |
|---|---|---|
| **SCARO** | : | Program Coordinator |
| **WVI** | : | Senior Program Manager |
| **PSE** | : | - Construction Training<br>- Managers and Trainers |
| **ARD** | : | - Trainees Requirement<br>- Resource Persons |

**Community Sanitation and Recycling Organization (SCARO)** is a local non-profit NGO, work with urban poor communities and waste pickers group cohesion to improve their standard of living and quality of life. CSARO is seeking a qualified Cambodian national (male or female) for the position as **Program Coordinator** base in Phnom Penh. The Program Coordinator is responsible for Assisting and support director in project planning, proposal writing and the overall management of the projects. Coordination and supervision of the program officer's activities of the project to achieve the goals. Prepare program activities quarterly reports in English submit to director. Develops and reviews job description and appraisals of program staff and officers.

**The requirement** of this post are Cambodian national aged from 35-45 years old preferred. Graduation qualification in Management. At least 5 years experience in Urban Development sector.

Interested applicants please submit CV, Cover Letter indicating position applied for and current photo (4x6) to the SCARO office #39, St 358, Toul Svay Prey1, Chamcarmon **not later than 06 April 2007.**

---

**World Vision** is seeking a qualified Cambodian national to fill a vacant position of **Senior Program Manager** for HIV/AIDS Program based in World Vision Phnom Penh.

Interested applicants should obtain an official WVC's application form and submit with CV and cover letter to HR Department, World Vision Cambodia office # 20, St 71, Tonle Basac, Chamcarmon or email cam_recruitment@wvi.org **not later than 20 April 2007.**

**Pour un Sourire d'Enfant(PSE)** is a French non-profit organization which has been established since 1995. PSE employs more than 400 dedicated staff. It provides training in different skills to maltreated, destitute and uneducated children who scavenge to survive on the dumpsite at Stung Meanchey. PSE is seeking for a Cambodian National for the vacant positions of:

1. CONSTRUCTION TRAINING MANAGER2
2. Three TRAINERS OF:

- electrician in construction
- plumbing and bathroom
- painting and tiling, based in Phnom Penh.

For more detail responsibility and requirement of each post, please visit Bongthom website.

Interested candidates are invited to submit their CV with photo and cover letter to PSE HR Department: - In French for Construction Training Manager

- In English or French for other positions

to PSE office # 402, Steung Meanchey, Phnom Penh or email recruitment@site-psc.org **not later than 09 April 2007.**

---

**Action for Research and Development 'ARD'** is seeking the Trainees for attending a new training course on **Training of Trainer (TOT)** which will take place in the weekends (Saturday and Sunday). The training will start on 19 May 2007 and facilitate by experience Trainers.

The course will cover in the main following topics:

- Adult learning principles
- Training Need Assessment (TNA)
- Training cycle and methodology
- Role of Trainers/Facilitators
- Training Designs
- Monitoring and evaluation of the training process

All students and young graduates from various Universities who interested this subject and **have available time as the date mentioned above** are invited to apply for participating this training course by submission **an updated CV with a current photo and a Letter of Interest** to ARD office: house # 51F, St 265, Teuk Laak3, Tuol Kuok, Phnom Penh. For more information please contact through phone number 016 77 87 01.

**Note:**

- **No any applications by email will received.**
- **The successful candidates have to contribute a small fee for the training course.**

***Deadline: May 5, 2007***

# ដំណឹងជ្រើសរើសបុគ្គលិក

## Resource Persons Requirement
## (Voluntary Service)

**Action for Research and Development (ARD) is a Cambodian Non-Governmental Organization** which had been running activity for almost one year, focused on Training, Newsletter Publication, Research, Community Development Project and Consultancy Service Provider.

*Currently, ARD are providing Consultancy Service (for Research and Training) and in the process of Building Confidential among NGOs/Institutions, Beneficiaries, and Donors by organizing and developing Training Courses for Young Graduates and NGO Staff, Newsletter Publication, Project Planning and Proposal Writing, Expanding the Training-Research Services.*

In order to run activity effectively according to the plan and reach our Objective *asap*, ARD are now ***seeking the Experience Resource Person Team (Voluntary Service)*** *to assist together with other Board Members, Founders and Voluntary Staff (who are currently playing the active and key roles) as ARD Family.*

**Responsibilities:** The Resource Persons will be responsible the following respective jobs:

1. ***Training and Research Team:*** Responsible for preparation and developing the Training Handout/Materials, Research Tools/Methodologies, and will play as Trainers during the Training Course conducted by ARD to Young Graduates/NGO Staff, and Consultancy Service Provider
2. ***Webpage Designing and Newsletter Publication Team:*** Responsible for designing the webpage and host the ARD information on website, search the information related to the ARD project activities, prepare and organize text for publishing ARD Monthly Newsletter.
3. ***Project Planning and Proposal Developing:*** Responsible for preparation and developing Strategic Plan, Project Proposal, and Building Good Communication and Relationship with other NGOs/Institutions.

**Main Note for Candidates:** The Resource Persons who were selected have to Carried Out their *Jobs as Part Time (at least available for working in the weekends)*. They will not get any salary and benefits but they *will have a good opportunity to get automatic receiving salary and benefits according to performance (in case they interested) when ARD get services and fund support*. The post is under coordination and supervision of Executive Director and closed collaboration with ARD Founders and Voluntary Staff.

**Requirement:**

1. **Training and Research Team:** must be have background and experiences in preparation Training Handout/Materials, Research Tools/Methodologies, and used to Facilitate in the Training Courses.
2. **Webpage Designing and Newsletter Publication:** Must be IT background and have experiences in designing Webpage and Publish Newsletter.
3. **Project Planning and Proposal Developing:** Must be have background/experiences and well understanding in Project Planning, Proposal Writing.

**Interest *candidates who are willingness to contribute in building new NGO, wishing to become Consultancy Group and join as part of ARD Family Members*** *with our Board Members, Founders, and Voluntary Staff* (***both Foreigners and Cambodians***) are invited to submit **Cover Letter and CV with a current photo** by specifying the Team whish to apply not later than **13 April 2007** to the ARD office: #51F, Street 265, Teuk Laak III, Tuol Kuok, Phnom Penh, CCC Box: 304
**Tel. :** (855) 16 77 87 01/ (855) 12 478 874. **E-mail :** ard.cambodia@yahoo.com

# កសិកម្ម និងការអភិវឌ្ឍន៍

## គេរកឃើញប្រភេទផ្តាសាយបក្សីនៅថៃ ធន់នឹងថ្នាំពេទ្យ

តាមការចុះផ្សាយរបស់ព្រឹត្តិបត្រ Cambodia Daily កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៧ បាន អោយដឹងថា ក្រុមអ្នកវិទ្យាសាស្ត្របានរកឃើញថា ប្រភេទនៃវីរុសផ្តាសាយបក្សី H5N1 ដែលកំពុងកើតមាននៅក្នុងប្រទេសថៃ គឺធន់នឹងថ្នាំប្រឆាំងមេរោគផ្តាសាយ អាម៉ាន់តាឌីន ហើយគេបានអំពាវនាវអោយមានការសិក្សាដ៏ម៉ត់ចត់នៃក្រុមប្រភេទ H5N1 ដើម្បីព្យាបាលជនរងគ្រោះ អោយបានប្រសើរ។

ខណៈដែលអង្គការសុខភាពពិភពលោក បានអោយអនុសាសន៍ដ៏យូរមកហើយថា ត្រូវប្រើឱសថ Tamiflu ជាខ្សែការពារដំបូងប្រឆាំងវីរុស H5N1នោះ អង្គការនេះបាននិយាយកាលពីខែឧសភាមុនថា "វិធីព្យាបាលរោគទ្វេ" ដោយរួមផ្សំថ្នាំអាម៉ាន់តាឌីន និង Tamiflu អាចត្រូវគេពិចារណាពេលកើតមានជំងឺ។

គួរកត់សំគាល់ថា ជំងឺផ្តាសាយបក្សី ជាជំងឺដ៏គួរអោយព្រួយបារម្ភមួយដែលបានកើតឡើងនាប៉ុន្មានឆ្នាំមុននេះ រហូតមកដល់ពេលបច្ចុប្បន្ន នៅក្នុងបណ្តាប្រទេសមួយចំនួន ជាពិសេសក្នុងតំបន់អាស៊ីអគ្នេយ៍ ដោយរួមបញ្ចូលទាំងព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ដែលបង្កអោយមានសត្វស្លាប់ និងបំផ្លាញចោលយ៉ាងច្រើន និងមនុស្សស្លាប់ផងដែរ។

យុង ពូវ៉ារ៉ាន ជាសាស្ត្រាចារ្យវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យជូឡាឡុងកន ក្នុងទីក្រុងបាងកក បាននិយាយថា ប្រភេទវីរុស H5N1 នៅភាគកណ្តាលនៃប្រទេសថៃធន់នឹងថ្នាំប្រឆាំង អាម៉ាន់តាឌីន ធ្វើអោយមានការងឿងឆ្ងល់ថែមទៀតអំពីការប្រើថ្នាំនេះដើម្បីប្រយុទ្ធនឹងជំងឺ។

សាស្ត្រាចារ្យយុង បាននិយាយថា "វាមុខជាគ្រោះថ្នាក់ណាស់ ប្រសិនបើយើងមិនដឹងភាពប្រែប្រួល រឺភាពធន់នៃប្រភេទវីរុសនេះ ចំពោះថ្នាំអាម៉ាន់តាឌីន ហើយយើងប្រើថ្នាំអាម៉ាន់តាឌីននេះ ដើម្បីព្យាបាលមនុស្សដែលឆ្លងវីរុស H5N1នេះ"។ គាត់បាននិយាយថា "ប្រសិនបើអ្នកតាមដានប្រភេទថ្មីណាមួយ អ្នកនឹងដឹងការប្រែប្រួលពន្ធុ អ្នកវិភាគរចនាសម្ព័ន្ធម៉ូលេគុលធ្វើពិសោធន៍ដើម្បីអោយដឹងថា ថ្នាំណាដែលវាឆ្លើយតប ហើយរកអោយឃើញថាការមកដល់មួយណា ដែលល្អជាងគេសំរាប់ប្រភេទវីរុសចំពោះប្រភេទដែលគេផ្តល់អោយនេះ"។

"វាដូចល្បែងផ្គុំរូប យើងត្រូវរកអោយឃើញបំណែកនានា ហើយនឹងឃើញរូបភាពធំ"។

សាស្ត្រាចារ្យយុង និងក្រុមអ្នកស្រាវជ្រាវរបស់គាត់បានធ្វើការសន្និដ្ឋានចុងក្រោយ បន្ទាប់ពីការសិក្សារចនាសម្ព័ន្ធម៉ូលេគុលនៃប្រភេទ ដែលកំពុងសាយភាយក្នុងប្រទេសថៃ ប្រទេសកម្ពុជា និងប្រទេសវៀតណាម ចាប់តាំងពីឆ្នាំ២០០៤មក។

ដោយសំដៅលើការពិសោធន៍ក្នុងទីពិសោធន៍ រឺការរៀបចំទុកផ្សេងទៀត គាត់បាននិយាយថា "យើងត្រូវការធ្វើការពិសោធន៍ខាងក្រៅភាវរស់"។

ទោះយ៉ាងណាក៏ដោយ គាត់មិនអាចនិយាយថា វិធីព្យាបាលទ្វេតាមីភ្លូ និងអាម៉ាន់តាឌីន (Tamiful-amantadine) មានប្រសិទ្ធិភាពយ៉ាងណានោះទេ ខណៈដែលប្រទេសថៃមិនបានសាកល្បងផ្តល់ការព្យាបាលបែបនេះ។

សាស្ត្រាចារ្យយុង បានប្រាប់ភិនភាគប្រភេទវីរុសមួយនៅភាគឥសាន្ត ខេត្តនគរភ្នំថា ដូចប្រភេទមាននៅខេត្តហ្វូចៀនប្រទេសចិន ដែលក្រុមវិសាទនូសាស្ត្រអន្តរ-ជាតិ បាននិយាយនៅខែតុលាថា អាចចាប់ផ្តើមការកើតមានវីរុស H5N1 ផ្សេងទៀតក្នុងបសុបក្សីនៅអាស៊ីអគ្នេយ៍ និងអាស៊ីអឺរ៉ុប។

ការកើតមានប្រភេទវីរុស H5N1 ផ្សេងគ្នាជាបញ្ហាកង្វល់ដ៏ខ្លាំង ពីព្រោះប្រភេទនីមួយៗឆ្លើយតបខុសៗគ្នាទៅនឹងថ្នាំប្រឆាំងវីរុស និងវ៉ាក់សាំងផ្សេងគ្នា។ លោកយុង បាននិយាយថា បើមានវីរុសច្រើនប្រភេទ ហើយវាខុសៗគ្នានោះ យើងនឹងមិនអាចដឹងពីប្រសិទ្ធិភាពនៃវ៉ាក់សាំងឡើយ។

# កសិកម្ម និងការអភិវឌ្ឍន៍

## សហរដ្ឋអាមេរិក និងប្រទេសកម្ពុជាធ្វើការរួមគ្នា ប្រយុទ្ធប្រឆាំងជំងឺផ្តាសាយបក្សី

មន្ត្រីគណៈកម្មាធិការជាន់ខ្ពស់ បានមានប្រសាសន៍ថា មេបញ្ជាការកងកំលាំងទាហានម៉ារីនរបស់សហរដ្ឋអាមេរិកប្រចាំតំបន់ប៉ាស៊ីហ្វិក បានស្នើសុំធ្វើការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា ដើម្បីដោះស្រាយជាមួយនឹងជំងឺគ្រុនផ្តាសាយបក្សីដែលអាចកើតមានឡើង (នេះបើតាមព្រឹត្តិបត្រ Cambodia Daily ចេញផ្សាយថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៧)។

លោកញឹម វណ្ណដា អនុប្រធានទី១ នៃគណៈកម្មាធិការនេះ បានមានប្រសាសន៍ថា លោក ហ្វូដមែន ចង់ធ្វើជាដៃគូរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីសំរបសំរួលនៅក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការកើតមានឡើងនៃជំងឺផ្តាសាយបក្សី ហើយលោកក៏បានសន្យាផ្តល់នូវជំនួយផងដែរ។

លោកញឹម វណ្ណដា បានមានប្រសាសន៍ថាលោក ហ្វូដមែន ពុំបានសំណូមពរវិធានការណាមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺផ្តាសាយបក្សីនោះទេ ប៉ុន្តែគណៈកម្មាធិការនេះបានប្រាប់លោកថា ទាហានកងយោធពលខេមរភូមិន្ទ ក្រសួងមហាផ្ទៃ កាកបាទក្រហមកម្ពុជា និងក្រសួងសុខាភិបាល ទាំងអស់គ្នានឹងធ្វើការរួមគ្នាក្នុងករណីនៃការកើតមានឡើងនូវជំងឺនេះ។

លោក ជេហ្វ ដាយហ្គល អ្នកនាំពាក្យស្ថានទូតអាមេរិកបានបញ្ជាក់ថា លោក ហ្វូដមែន បានជួបជាមួយរដ្ឋាភិបាល យោធា និងអ្នកតំណាងផ្នែកឯកជន ដែលកំពុងធ្វើការក្នុងកិច្ចខិតខំប្រឹងប្រែងរៀបចំផែនការដែលអាចកើតមានឡើងទូទាំងប្រទេស។

លោកដាយហ្គល បានសរសេរនៅក្នុងអ៊ីម៉ែលមួយថា លោកហ្វូដមែន បានចង្អុលបង្ហាញថា មេបញ្ជាការប្រចាំតំបន់ប៉ាស៊ីហ្វិករបស់សហរដ្ឋអាមេរិកកំពុងរិះរកមធ្យោបាយនានាដែលអាចជួយប្រទេសកម្ពុជាក្នុងការត្រៀមរៀបចំការកើតមានឡើងដែលអាចទៅរួច។ លោកដាយហ្គល បានមានប្រសាសន៍ថា "ការបណ្តុះបណ្តាលគឺទំរង់មួយនៃការជួយដែលអាចទៅរួច ដូចជាសិក្ខាសាលាមួយសំរាប់យោធាកម្ពុជា ជាអ្នកឆ្លើយតបទីមួយថា (មេបញ្ជាការតំបន់ប៉ាស៊ីហ្វិកសហរដ្ឋអាមេរិក) បានរៀបចំកាលពីខែមុន។

គួររំលឹកផងដែរថា ជំងឺផ្តាសាយបក្សី ជាជំងឺមួយដ៏កាចសាហាវដែលធ្វើអោយប្រជាពលរដ្ឋកម្ពុជាចំនួន ៦នាក់ បានស្លាប់ដោយសារជំងឺនេះ កាលពីចន្លោះខែកុម្ភៈ ឆ្នាំ២០០៥ និងខែមេសា ឆ្នាំ២០០៦។ ហើយជំងឺផ្តាសាយបក្សីនេះ ក៏បានរាតត្បាតខ្លាំងជាងនៅព្រះរាជាណាចក្រកម្ពុជាទៀត ក្នុងប្រទេសឥណ្ឌូនេស៊ី ថៃ វៀតណាម ឡាវ និងប្រទេសមួយចំនួនទៀតផងដែរ។

លោកកែវ ផល ដែលជាប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា ស្ថានភាពជំងឺផ្តាសាយបក្សីនៅក្នុងប្រទេសនាពេលបច្ចុប្បន្ននេះមានភាពស្ងប់ស្ងាត់ហើយ។

**ជំងឺផ្តាសាយបក្សី គឺជាជំងឺឆ្លងដែលអាចសំលាប់មាន់-ទាយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងរយៈពេលដ៏ខ្លី។ ជំងឺនេះអាចឆ្លងពីសត្វមកមនុស្ស ហើយអាចបណ្តាលអោយស្លាប់ ហេតុនេះសូមប្រជាពលរដ្ឋទូទៅ ចូលរួមនៅក្នុងបង្ការមិនអោយឆ្លងជំងឺផ្តាសាយបក្សី ដោយ :**

**១. មិនត្រូវអោយកុមារលេង រឺប៉ះពាល់មាន់-ទា រឺសត្វស្លាបផ្សេងៗទៀតឡើយ ជាពិសេសមាន់-ទាដែលឈឺ រឺងាប់**

**២. សូមលាងដៃអោយបានស្អាតជាមួយសាប៊ូ រឺផេះ ក្រោយពេលប៉ះពាល់មាន់-ទា**

**៣. សាច់មាន់-ទា និងពងរបស់វាត្រូវចំអិន អោយឆ្អិនល្អសព្វកន្លែង ធ្វើយ៉ាងណាកុំអោយមានឈាម រឺឆៅ**

**៤. មិនត្រូវយកមាន់-ទា ដែលឈឺ រឺងាប់ ដោយសារជំងឺមកធ្វើជាអាហារ**

**៥. បើមានមាន់-ទា ឈឺ រឺងាប់ ត្រូវរាយការណ៍ជាបន្ទាន់ដល់ពេទ្យសត្វ រឺទូរស័ព្ទទៅលេខ ០១២ ២១៤ ៩៧០។**

**៦. បើសង្ស័យថាមានជំងឺផ្តាសាយបក្សីលើមនុស្ស សូមបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់ រឺទូរស័ព្ទ ០១២ ៤៨៨ ៩៨១។**

# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## បន្លែបន្ការ ដីសើម និងសំរាម : ការធានាសុវត្ថិភាពស្បៀង នៅភ្នំពេញ ប្រទេសកម្ពុជា

ដោយយល់ឃើញថា វាមានសារៈសំខាន់សំរាប់ជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាយើង នៅលេខនេះ ពតិមានសំខាន់សំរាប់អ្នក សូមលើកយកនូវលទ្ធផលសិក្សាស្រាវជ្រាវ របស់លោក មឿង ស៊ីដេត មន្ត្រីក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ដែលបានសិក្សាអង្កេតវាយតំលៃពីតំបន់ដីសើមនៅបឹងត្របែក បឹងទំពុន និងបឹងជើងឯក។ តាមរយៈគេហទំព័ររបស់កម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ (Economy and Environment Program for South East Asia) ដែលមានអាសយដ្ឋាន http://www.eepsea.org បានអោយដឹងថា នៅទូទាំងអាស៊ីអាគ្នេយ៍ អ្នកប្រើប្រាស់ និងអ្នកវិទ្យាសាស្ត្រ មានការចាប់អារម្មណ៏កាន់តែច្រើនពីវត្តមានសារធាតុគីមីក្នុងចំណីអាហារ។ ចាប់ពីសារធាតុបង្កជំងឺមហារីកមាននៅក្នុងទឹកដោះគោ រហូតដល់សំណល់ថ្នាំសំលាប់សត្វល្អិតលើបន្លែ អាហារមានជាតិគីមី គឺជាបញ្ហាបរិស្ថានចំបងមួយ។ នៅទីក្រុងភ្នំពេញ រឿងនេះគួរអោយបារម្ភជាពិសេស ពីព្រោះបន្លែភាគច្រើន គេដាំនៅតំបន់ដីសើមធ្លាប់ជាកន្លែងចាក់សំរាមទីក្រុង និងកាកសំណល់ឧស្សាហកម្ម ដែលធ្វើអោយបន្លែងនៅក្នុងស្រុកជាច្រើន ចោទជាបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ ព្រោះវាផ្ទុកទៅដោយជាតិពុល ដូចជាលោហៈធ្ងន់ (សំណ, បារត) និងជាតិពុលដទៃទៀត។

ការសិក្សាថ្មីមួយបានពិនិត្យពីវិធីទប់ស្កាត់ការដាំដុះបន្លែមានជាតិគីមីបែបនេះ ដែលត្រូវមានសំណងប៉ះប៉ូវយ៉ាងសមរម្យសំរាប់កសិករដែលត្រូវប៉ះពាល់។

### តំបន់ដីសើម ភាគសំណល់សំរាម

លោក មឿង ស៊ីដេត នៃក្រសួងបរិស្ថានកម្ពុជា បានរាយការណ៏ពីរឿងនេះថា ដំណោះស្រាយដែលមានប្រសិទ្ធិភាពចំណាយល្អបំផុត គឺកសិករ ដែលកំពុងដាំដុះលើដីសើមមានជាតិពុល ផ្លាស់ប្តូរទីតាំងដាំដុះ ដោយមានបំពាក់ប្រព័ន្ធស្រោចស្រពអោយកន្លែងថ្មី ដែលប្រើប្រាស់ទឹកកាកសំណល់ពីការប្រើប្រាស់តាមគ្រួសារ ដែលបានច្រោះសំអាតរួច។ ការដាំដុះលើដីថ្មីនេះត្រូវរួមផ្សំ ជាមួយយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ ដើម្បីពន្យល់ពីគ្រោះថ្នាក់នៃការបរិភោគបន្លែមានជាតិគីមី។

**លោកមឿង ស៊ីដេត និងក្រុមរបស់គាត់ បានអង្កេតមើលតំបន់ដីសើមបឹងត្របែក បឹងទំពុន បឹងជើងឯក។ តំបន់ទាំងនេះ ស្ថិតនៅក្បែរទីក្រុងភ្នំពេញ ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រូបយកទឹកជន់លិច និងកាត់បន្ថយបរិមាណជាតិពុល ដែលហូរចូលទៅក្នុងផ្លូវទឹកនៅជុំវិញនោះ។** ជាតួលេខសរុប តំបន់ដីសើមទទួលយកទឹកសំណល់ ក្រោយពីប្រើប្រាស់តាមគ្រួសារប្រចាំថ្ងៃរហូតដល់ ៥៥ ៦០០ ម៉ែត្រគូប ពីប្រជាពលរដ្ឋជាង ៦៥៣ ០០០គ្រួសារ (ស្មើនឹង៦,៦ តោន នៃការបញ្ចេញចោល នៃតំរូវការអុកស៊ីហ្សែនជីវសាស្ត្រ BOD 5ក្នុងមួយថ្ងៃ) និងទឹកកាកសំណល់ បង្ហូរចេញពីជាង ៣ ០០០ រោងចក្រឧស្សាហកម្ម។

### ការតាំងទីលំនៅថ្មី នឹងផ្តល់ផលប្រយោជន៍ច្រើនដល់កសិករ :

តំបន់ដីសើម គឺជាកន្លែងស្តុកទឹកសំណល់ ពីព្រោះភ្នំពេញពុំមានលូទឹកស្អុយគ្រប់គ្រាន់ និងពុំមានមធ្យោបាយសំអាតទឹកសំណល់ទេ។ ប្រព័ន្ធលូទឹកស្អុយក្នុងទីក្រុង ដែលភាគច្រើនបានកសាងឡើងក្នុងទសវត្សរ៏១៩៦០ ទទួលទឹកសំណល់ពីការប្រើប្រាស់តាមគ្រួសារ ពីលូបង្ហូរទឹកភ្លៀងចេញ និងលូរោងចក្រឧស្សាហកម្ម។ ចំពោះទឹកសំណល់ចេញពីប្រភពទាំងនេះ ១០% ហូរចូលដោយផ្ទាល់ទៅទន្លេមេគង្គ ដោយគ្មានការសំអាត ហើយ៩០%ដែលនៅសល់ត្រូវស្តុកនៅក្នុងតំបន់ដីសើមធម្មជាតិជុំវិញទីក្រុង។ កសិករជិត ៣០០គ្រួសារ ធ្វើការដាំដុះលើតំបន់ដីសើមនេះ ហើយផលិតបន្លែស្រស់បាន១២មុខ។ ជារៀងរាល់ថ្ងៃ ពួកគេផលិតបានប្រហែល ២៦តោន គឺប្រមាណ ២០% នៃបរិមាណបន្លែលក់ចេញសរុបនៅក្នុងទីក្រុងភ្នំពេញ។ កសិករដែលដាំដុះនៅតំបន់នេះ មានជីវភាពសមរម្យ ជាពិសេសកសិករនៅតំបន់បឹងត្របែក ដែលអាចរកចំណូលបាន ២៧ដុល្លារក្នុងមួយថ្ងៃក្នុងមួយគ្រួសារ ធៀបនឹងកំរិតបៀវត្សរ៏អប្បបរមាតាមច្បាប់របស់រដ្ឋតែត្រឹម ១,៥ដុល្លារ នៅភ្នំពេញ ។ ***(មានតនៅលេខក្រោយ)។***

# ជីវិត និងសង្គម

## ក្រុមមន្ត្រី និងកងរាជអាវុធហត្ថ បានដុតបំផ្លាញផ្ទះ១៣០ខ្នង នៅក្នុងព្រៃដែនការពារ

វាជាការគួរអោយសរសើរ និងមោទនភាពណាស់ ដែលព្រះរាជាណាចក្រកម្ពុជាយើងមានច្បាប់ជាច្រើន ហើយដែលភាគច្រើននៃច្បាប់ទាំងអស់ សុទ្ធតែមានចំនុចល្អប្រសើរ សំរាប់ដាក់ទោសទណ្ឌដល់អ្នកប្រព្រឹត្តិល្មើសអោយរាងចាល។ ប៉ុន្តែផ្ទុយទៅវិញ វាជាការគួរអនិច្ចារ និងសង្វេកជាពន់ពេក នៅពេលដែលព្រះរាជាណាចក្រនេះសំបូរ និងពោរពេញទៅដោយច្បាប់ ដែលចែងតែនៅក្នុងសៀវភៅ ហើយការអនុវត្តបទល្មើសនានានៅតែកើតមានឡើង និងរីករាលដាលឥតឈប់ឈរ។ ទាំងនេះឆ្លុះបញ្ចាំងអោយឃើញថា វាមិនសំខាន់នៅលើការមានច្បាប់នោះឡើយ តែអ្វីៗគឺអាស្រ័យលើឆន្ទៈរបស់អ្នកដឹកនាំ អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការអនុវត្តច្បាប់។ អ្នកល្មើសច្បាប់ ត្រូវតែទទួលទោស ទោះជាមានប្រាក់ មានបុណ្យស័ក្តិធំមហាមេឃ ប៉ុណ្ណាក៏ដោយ។ ហើយការកាត់ក្តីត្រូវតែយុត្តិធមិ និងឈរលើគោលការណ៏ស្មើភាពសំរាប់មនុស្សទូទៅ ដូចដែលរដ្ឋធម្មនុញ្ញបានសរសេរ។

បើតាមការចុះផ្សាយរបស់ Cambodia Daily ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៧ បានអោយដឹងថា កងរាជអាវុធហត្ថ និងមន្ត្រីរដ្ឋាភិបាលព្រៃឈើ នៅក្នុងខេត្តព្រះវិហារ បានបំផ្លាញផ្ទះឈើជិត ១៣០ខ្នង ដែលភាគច្រើននៃផ្ទះទាំងនោះមិនមានមនុស្សនៅ ហើយត្រូវបានសាងសង់ឡើងដោយក្រុមអ្នកភូមិនៅលើដីព្រៃឈើដែនការពារ។

បើតាមប្រសាសន៏របស់អភិបាលរងខេត្តមួយរូប បានអោយដឹងថា បន្ទាប់ពីបានទទួលដំណឹងថា រដ្ឋាភិបាលមានគំរោងសាងសង់ផ្លូវក្រាលកៅស៊ូនៅលើផ្លូវដីមួយកន្លែងនៅក្នុងឃុំដែលជាផ្លូវតភ្ជាប់ពីខេត្តព្រះវិហារ និងខេត្តសៀមរាបនោះ "អ្នកឆ្លៀតឱកាសបានចាប់យកដីនោះ ខណៈពេលដែលក្រុមអជ្ញាធរក្នុងមូលដ្ឋានរវល់នឹងយុទ្ធនាការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ "។ អភិបាលរងរូបនេះ បានបន្តថា ផ្ទះចំនួន២៥ខ្នងក្នុងចំណោមផ្ទះទាំងនោះមិនមានមនុស្សនៅទេ ចំណែកឯផ្ទះដទៃទៀតត្រូវបានគេសង់ដើម្បីចាប់យកដីនៅក្នុងភូមិស្រយ៉ង់ ស្រុកគូលេន ហើយដែលត្រូវបានក្រុមមន្ត្រីបានរុះរើ និងដុតបំផ្លាញចោល។

មន្ត្រីដែលជាអភិបាលរងមួយរូបផ្សេងទៀតរបស់ខេត្តនេះ បានមានប្រសាសន៏ថា ប្រជាជនកំពុងតែរានព្រៃយកដី ដើម្បីសង់ខ្ទម ពីព្រោះតំលៃដីបានកើនឡើងយ៉ាងខ្ពស់មុនពេលការសំរេចចិត្តមួយរបស់រដ្ឋាភិបាល ក្នុងការសាងសង់ផ្លូវដោយក្រាលកៅស៊ូ។

លោកចាន់ សុវ៉េត អ្នកស៊ើបអង្កេតនៅអង្គការសិទ្ធិមនុស្សអាដហុក បានមានប្រសាសន៏ថា ក្រុមអ្នកភូមិបានសាងសង់ផ្ទះកាលពីខែមុន បន្ទាប់ពីបានបង់ប្រាក់ពី ៣៧,៥០ ទៅ៥០ ដុល្លារ អោយក្រុមអជ្ញាធរមូលដ្ឋាន ដើម្បីសាងសង់ផ្ទះនៅលើដែនការពារ។ លោកបានមានប្រសាសន៏ថា អ្នកភូមិមិនអាចរានយកដីបានទេ ប៉ុន្តែលោកបានចោទប្រកាន់ផងដែរដល់ក្រុមអជ្ញាធរពីបទគំរាមកំហែងអ្នកតាំងលំនៅដ្ឋានទាំងនោះ និងពីបទដុតបំផ្លាញផ្ទះ និងទ្រព្យសម្បត្តិរបស់ពួកគាត់។

ដូចដែលបានលើកឡើងពីខាងដើម ពតិមានសំខាន់សំរាប់អ្នក ទទួលរីករាយនូវរាល់ដំណើរការទាំងឡាយណាដែលអនុវត្តតាមតាមច្បាប់ ព្រោះបើមិនដូច្នោះទេ វាជាការលើកទឹកចិត្ត និងធ្វើអោយបទល្មើសនានានៅតែកើតមានឡើង និងរីករាលដាល។ ប៉ុន្តែអ្វីដែលពតិមានសំខាន់សំរាប់អ្នក ធ្វើការកត់សំគាល់នោះ គឺសូមអោយគ្រប់អជ្ញាធរមានសមត្ថកិច្ចទាំងអស់ចាត់វិធានការណ៏ដើម្បីប្រឆាំងនឹងបទល្មើសនានា អោយសមស្របទៅនឹងវិធានដែលមានចែងក្នុងច្បាប់ ជៀសវាងការប្រើអំពើហឹង្សា រឺវិធានការទាំងឡាយណាដែលប៉ះពាល់ដល់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។

**<u>សូមរួមគ្នាគោរពច្បាប់ទាំងអស់គ្នា ដើម្បីសង្គមកម្ពុជាមានភាពរុងរឿង និងជានីតិរដ្ឋពិតប្រាកដឥតក្លែងក្លាយ។</u>**

# ជីវិត និងសង្គម

## បេក្ខភាពប្រាសាទអង្គរវត្ត ត្រឹមថ្ងៃទី១៥ មីនា ២០០៧ ស្ថិតនៅជួរទី២ សូមបន្តបោះឆ្នោតគាំទ្រ

តាមការចុះផ្សាយរបស់កាសែត កោះសន្តិភាព ចេញថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៧ បានអោយដឹងថា គិតត្រឹមថ្ងៃទី ១៥ ខែមីនាកន្លងមកនេះ ការបោះឆ្នោតគាំទ្រដល់ប្រាសាទអង្គរវត្តដែលជាបេតិកភណ្ឌជាតិខ្មែរ គឺមានតំលៃថេរគួរអោយរំពឹងទុកថា ប្រាសាទអង្គរវត្ត ដែលជាស្នាដៃបុព្វបុរសខ្មែរបន្សល់ទុក៩សតវត្សមកនេះ នឹងមានភ័ព្វវាសនាឈរនៅក្នុងលំដាប់ នៃអច្ឆរិយវត្ថុ៧ថ្មីលើពិភពលោកនេះ ក្នុងការប្រកួតប្រជែងជាបេក្ខភាពមួយ ក្នុងចំណោមបេតិកភណ្ឌល្បីៗលើពិភពលោក ចំនួន២០ផ្សេងទៀត។

**សំលេងឆ្នោតគាំទ្រប្រាសាទអង្គរដែលបានរក្សានូវសំលេងថេរនេះ គឺបន្ទាប់ពីចាប់ផ្តើមបើកការបោះឆ្នោតនៅតាម អ៊ីនធើរណេតក្នុងរយៈពេល១សប្តាហ៍កន្លងមក ត្រឹមដំណាច់ខែមករា ឆ្នាំ ២០០៧ (៣១ មករា) គឺបានឈរក្នុងជួរទី២ ក្នុងចំណោមអច្ឆរិយៈវត្ថុចំនួន៧ ដែលជាការកំណត់សំរាប់សំលេងគាំទ្របន្ទាប់ពីជួរទី១ តែរហូតមកដល់ត្រឹមថ្ងៃទី១៥ ខែមីនា កន្លងមកនេះ ប្រាសាទអង្គរបានស្ថិតនៅយ៉ាងរឹងមាំក្នុងជួរទី២ នាំមុខអច្ឆរិយវត្ថុចំនួន១១។**

*មានការកត់សំគាល់ថា អច្ឆរិយវត្ថុមួយចំនួនដែលធ្លាប់ឈរនៅជួរទី១ និងទី២ បានធ្លាក់មកឈរនៅជួរទី៣ ហើយអច្ឆរិយវត្ថុខ្លះដែលឈរនៅជួរទី៣ បានឡើងដល់ជួរទី១ ដូច្នេះមិនមានន័យថា បេតិកភណ្ឌណាមួយនាំមុខពិតប្រាកដនៅឡើយទេ ហើយការបង្ហាញត្រឹមពាក់កណ្តាលខែមីនានេះ គឺជាលទ្ធផលបណ្តោះអាសន្នប៉ុណ្ណោះ។* មុននេះមានប្រភពខ្លះថា មូលនិធិអច្ឆរិយវត្ថុ៧ថ្មីលើពិភពលោក នឹងមានការប្រកាសលទ្ធផលបណ្តោះអាសន្នមួយ នៅថ្ងៃទី៧ មីនា លើរូបសំណាកសេរីភាពនៅសហរដ្ឋអាមេរិក តែរហូតមកដល់ពេលនេះ មិនមានការប្រកាសលទ្ធផលនោះទេ។ ការបោះឆ្នោតដែលកំពុងដំណើរការនេះ នឹងបានបញ្ចប់ត្រឹមថ្ងៃទី៦ ខែកក្កដា ហើយនឹងប្រកាសលទ្ធផលជាផ្លូវការនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៧ (៧-៧-៧)។ មូលនិធិនេះមានទីតាំងស្ថិតនៅក្នុងទីក្រុងលីសបោន ប្រទេសព័រទុយហ្កាល់។

សំរាប់ប្រជាពលរដ្ឋខ្មែរ ការបោះឆ្នោតគាំទ្របេតិកភណ្ឌជាតិនេះតាមគេហ-ទំព័រ www.new7wonders.com ពិតជាមានការលំបាក ប្រសិនបើមិនមានគេហ-ទំព័រ (វេបសាយ) ផ្ទាល់ខ្លួនទេនោះ។ ការគ្មានវេបសាយផ្ទាល់ខ្លួននេះ ដោយសារកម្ពុជាមិនមានអ្នកប្រើប្រាស់អ៊ីនធ័រណេតផ្ទាល់ខ្លួន រឺមានប្រើតិចតួចបំផុត ព្រោះវាតំរូវអោយអ្នកប្រើចេះភាសា ត្រូវមានលទ្ធភាពទិញកុំព្យូទ័រភ្ជាប់បណ្តាញ និងត្រូវចំណាយលុយទាំងអស់។ ហេតុនេះហើយការផ្ញើសារទៅកានវេបសាយ ដែលមានអាស័យដ្ឋាន www.new7wonders.com តែជួបប្រទះបញ្ហាលំបាកសំរាប់ប្រជាពលរដ្ឋខ្មែរភាគច្រើន។

មតិខ្លះបាននិយាថា ការកង្វល់ពីបញ្ហាខាងលើ គ្រាន់តែជាការបង្ហាញពីស្មារតីលើកស្ទួយបេតិកភណ្ឌជាតិក្នុងនាមកូនចៅខ្មែរប៉ុណ្ណោះ បើគិតពីចំនួនប្រជាជនខ្មែរដែលមានជាង១៣លាននាក់វិញ គឺចំនួននេះតិចតួចណាស់ មិនស្មើនឹងចំនួនប្រជាពលរដ្ឋគេក្នុងទីក្រុងមួយផង ហេតុនេះការគាំទ្រពិតប្រាកដនោះ គឺការផ្តល់តំលៃជាអន្តរជាតិ មានភាពទូលំទូលាយ ដែលនេះក៏ជាក្តីសង្ឃឹមមួយសំរាប់ប្រាសាទអង្គរនៃយើងដែរ ដែលក្នុងមួយថ្ងៃៗអ្នកទេសចរបរទេសបានហូរចូលរាប់ពាន់នាក់ គឺពួកគេនោះហើយដែលជាអ្នកគាំទ្រយ៉ាងកក់ក្តៅសំរាប់ប្រាសាទអង្គរ នៃព្រះរាជាណាចក្រកម្ពុជា។

**យោងតាមលទ្ធផលខាងលើ**

**ឃើញថា ប្រាសាទអង្គរវត្តនៅមិនទាន់ស្ថិតនៅក្នុងលំដាប់នៃអច្ឆរិយវត្ថុទាំង៧ នៅឡើយទេ ព្រោះស្ថិតនៅក្នុងជួរទី២ ដែលទាំងអស់មាន៣ជួរ ហើយមួយជួរមានចំនួន៧អច្ឆរិយវត្ថុ។ ហេតុនេះ សូមប្រជាពលរដ្ឋកម្ពុជាទាំងអស់ រួមជាមួយពលរដ្ឋនៅទូទាំងពិភពលោក បន្តបោះឆ្នោតអោយប្រាសាទអង្គរវត្តថែមទៀត ដើម្បីអោយប្រាសាទអង្គរស្ថិតនៅក្នុងជួរទី១។**



# ទំព័រចុងក្រោយសំរាប់អ្នក

## សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក

| LE CRI D’APPEL DE « ANGKOR WAT » |
|---|
| សំរែកប្រាសាទអង្គរវត្ត |
| THE CRY OF CALL OF « ANGKOR WAT » |

**<< EMMENEZ-MOI AU « 7 MERVEILLES DU MONDE »;
VOUS SEREZ TRES NOBLEMENT HONORE >>**

**<<សូមមេត្តាជួយនាំអោយខ្ញុំបានដល់ "អច្ឆរិយវិមានពិភពលោកទាំង៧"**

**លោកអ្នកនាង នឹងមានមហាកិត្តិយសដ៏ឧត្តុង្គឧត្តម >>**

**<< TAKE ME ALONG TO THE « 7 WONDERS OF THE WORLD »;**

***YOU WILL VERY NOBLEMENT BE HONOURED >>***

******

**- Ensemble, aidons-le ; soutenons-le ; emmenons-le jusqu’au
« 7 Merveilles du Monde » et donc, mobilisons-nous, s’il vous plait, merci.**

**- ទាំងអស់គ្នា ចំជួយ ចំគាំទ្រ ចំនាំប្រាសាទយើង អោយបានដល់**

**"អច្ឆរិយវិមានពិភពលោកទាំង៧"ៗ ពួដូច្នេះយើងត្រូវកេណ្ឌកម្លាំងគ្នា, សូមអគុណៗ**

**- Together, let us help it, let us support it, it along until the « 7 wonders
of the world », and we mobilize take, please, thank you.**

## Vote: www.new7wonders.com

**Comité de Soutien « ANGKOR Wat » à l’élection des « 7 Merveilles du Monde »**
**E.mail : haing-kheang.lim@wanadoo.fr**